# ការពង្រឹងវិស័យសំខាន់ៗ ដើម្បីសំរេចបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ ការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា៖ ហេដ្ឋារចនាសម្ព័ន្ធ និងថាមពល

ប្រទេសកម្ពុជាមួយផ្នែកដោយសារហេតុការណ៍ក្នុងប្រវត្តិសាស្រ្ត ដែលគេអាចយល់បាននោះផង បានទទួលរងគ្រោះយ៉ាងខ្លាំងពីកង្វះការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក និងថាមពល ។ ដើម្បីអាចឈានដល់កំណើនខ្ពស់ប្រកបដោយចីរភាព គេត្រូវដោះស្រាយឲ្យបានសក្តិសិទ្ធិ នូវកង្វះខាត និងកត្តារាំងស្ទះផ្សេងៗ ដែលកម្ពុជាកំពុងជួបប្រទះក្នុងវិស័យនេះ ។ ទោះបីជាហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទ ត្រូវបានកែលំអបានច្រើនហើយក្នុងប៉ុន្មានឆ្នាំថ្មីៗនេះក្តី ប៉ុន្តែវិស័យនេះ នៅមានកំហិតច្រើនសន្ធឹកទៀត ដែលធ្វើឱ្យផលិតករនៅកម្ពុជា ត្រូវចាញ់ប្រៀបគេក្នុងការប្រកួតប្រជែង ហើយការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចជាទូទៅនៅកម្ពុជា ក៏ជួបឧបសគ្គធំធេង ។ អត្ថបទនៅខាងក្រោមនេះ ជាសេចក្តីសង្ខេបលើបទបង្ហាញរបស់ឯកឧត្តម បណ្ឌិត ហង់ ជួន ណារ៉ុន[១] ឯកឧត្តម ហាវ រតនៈ[២] និងលោក David Kerr[៣] ដែលបានពិភាក្សាវែកញែកពីស្ថានភាពសារៈសំខាន់ និងការរំពឹងទុក ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ។

បណ្ឌិត ណារ៉ុន បានពិនិត្យពីតួនាទីហេដ្ឋារចនាសម្ព័ន្ធក្នុងន័យទូលំទូលាយនៃការចូលរួមចំណែកក្នុងវិបុលភាព និងការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា ដោយបានញែកចេញពីគ្នានូវហេដ្ឋារចនាសម្ព័ន្ធប្រភេទខុសៗគ្នា និងធ្វើការថ្លឹងថ្លែងពិចារណាក្នុងបរិបទនៃគោលការណ៍ខាងភូមិសាស្រ្តនយោបាយដ៏ចាំបាច់ សំរាប់កំណើនរយៈពេលវែង ។

លោកបណ្ឌិត បានលើកពីហេដ្ឋារចនាសម្ព័ន្ធពីរប្រភេទធំៗគឺ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ក្របខ័ណ្ឌច្បាប់ (hard and soft infrastructure) ដោយចង្អុលបង្ហាញថា ជាលក្ខណៈប្រវត្តិសាស្រ្ត ហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទ បានល្អប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ ។ ឧទាហរណ៍ ក្នុងការស្តារជួសជុលផ្លូវថ្នល់ មានផ្លូវថ្នល់ប្រវែង ៥៥០គីឡូម៉ែត្រ ត្រូវបានស្តារឡើងនៅអំឡុងឆ្នាំ១៩៩៣-១៩៩៧ ផ្លូវថ្នល់ប្រវែង ២៣៥០គីឡូម៉ែត្រ នៅអំឡុងឆ្នាំ១៩៩៨-២០០៣ នឹង ៦០០គីឡូម៉ែត្រ នៅអំឡុងឆ្នាំ២០០៤-២០០៧ ។ ក្នុងពេលថ្មីៗនេះ ទូរគមនាគមន៍ ជាពិសេសទូរស័ព្ទចល័ត និងការប្រើប្រាស់អ៊ីនថឺណិត បានកើនឡើងប្រមាណ ៥០%ក្នុងមួយឆ្នាំ ។ លោកបានវែកញែកទៀតថា កម្ពុជាបានស្តារ និងកសាងឡើងវិញយ៉ាងច្រើននូវបណ្តាញដឹកជញ្ជូន ដូចជា ផ្លូវថ្នល់ ផ្លូវទឹក ផ្លូវដែក និងអាកាសយានដ្ឋាន ។

ផ្លូវដែកនៅកម្ពុជា រំពឹងថា នឹងមានការកែលំអគួរឲ្យកត់សម្គាល់ ។ នៅខែមីនា ២០០៧ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាជាមួយធនាគារអភិវឌ្ឍន៍អាស៊ី លើគំរោងស្តារផ្លូវដែកនៅកម្ពុជា ដែលមានទឹកប្រាក់ចំនួន ៧៣លានដុល្លារអាមេរិក ដោយក្នុងនោះ ភាគីកម្ពុជាត្រូវចូលរួមវិភាគទាន ១៥លានដុល្លារអាមេរិក ។ គំរោងនេះ រួមមានការសាងសង់ផ្លូវដែកប្រវែង ២៥៧គីឡូម៉ែត្រ ពីភ្នំពេញទៅ Loc Ninh ។ រាជរដ្ឋាភិបាល ក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសម្បទានមានរយៈពេល ៣០ឆ្នាំ ជាមួយក្រុមហ៊ុនអូស្រ្តាលី Toll Holdings លើការធ្វើប្រតិបត្តិការផ្លូវដែក ក្នុងទម្រង់ជាក្រុមហ៊ុនសហកម្មសិទ្ធិរវាងរដ្ឋ និងឯកជន និងចុះហត្ថលេខាជាមួយក្រុមហ៊ុនបារាំង TSO លើការស្តារផ្លូវដែកឡើងវិញ ។

ទាក់ទិននឹងក្របខ័ណ្ឌច្បាប់ បណ្ឌិត ណារ៉ុន បានវិភាគគាំទ្រដល់កិច្ចការពារកម្មសិទ្ធិបញ្ញា ការចុះបញ្ជីដីធ្លីជាលក្ខណៈប្រព័ន្ធការិយាល័យច្រកចេញចូលតែមួយ សំរាប់ជួយសំរួលកាត់បន្ថយរយៈពេលផ្តល់ការអនុម័តយល់ព្រម និងចំណាយប្រតិបត្តិការ ព្រមទាំងការកែលំអបរិយាកាសពាណិជ្ជកម្ម តាមរយៈកំណែទម្រង់អភិបាលកិច្ចផ្សេងៗ ។ ការសំរបសំរួលពាណិជ្ជកម្ម ក៏ដូចជាការដឹកជញ្ជូនឆ្លងកាត់ព្រំដែន និងធានារ៉ាប់រង ក៏ត្រូវមានអាទិភាពខ្ពស់ដែរ ។

ក្នុងការប្រមើលមើលពី វិស័យហេដ្ឋារចនាសម្ព័ន្ធ បណ្ឌិត ណារ៉ុន បានពិភាក្សាលើប្រធានបទទាក់ទងនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីហេដ្ឋារចនាសម្ព័ន្ធ និងតួនាទីរបស់វាក្នុងការសំរេចបានគោលដៅអភិវឌ្ឍន៍របស់កម្ពុជា ។ គោលនយោបាយនេះ មានសមាសធាតុសំខាន់ៗដូចតទៅ៖

- ការស្តារជួសជុល និងសាងសង់ ផ្លូវជាតិនិងផ្លូវខេត្ត ផ្លូវដែក អាកាសយានដ្ឋាន កំពង់ផែ និងប្រព័ន្ធធារាសាស្រ្ត
- ទូរគមនាគមន៍អេឡិចត្រូនិក ផលិតកម្មនិងបណ្តាញចែកចាយអគ្គិសនី
- ការទាក់ទាញវិស័យឯកជនឲ្យធ្វើវិនិយោគ លើការងារសាធារណៈ (BOT-សាងសង់-អាជីវកម្ម-ផ្ទេរ) ក្នុងក្របខ័ណ្ឌជាសម្បទាន ។

---

១ រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានអចិន្ត្រៃយ៍ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និង ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន CDRI ។

២ អនុប្រធាននាយកដ្ឋានថវិកា មន្ត្រីត្រួតពិនិត្យរដ្ឋអមអគ្គិសនីកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង អគ្គលេខាធិការរងនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ។

៣ អគ្គនាយកក្រុមហ៊ុន Toll កម្ពុជា ។

ការស្ដារជួសជុល និងកែលំអហេដ្ឋារចនាសម្ព័ន្ធ មានគោលដៅចំបង ជួយសំរួលដល់របៀងកំណើននៅកម្ពុជា និងមានជាអាទិ៍ តភ្ជាប់ប៉ូលកំណើននានានៅកម្ពុជា ហើយក្នុងពេលជាមួយគ្នា ធ្វើការកែលម្អ និងដំណើរការឲ្យបានជាក់ស្ដែង នូវរបៀងសេដ្ឋកិច្ចមេគង្គ-តណ្ហ ដើម្បីជួយសំរួលដល់ពាណិជ្ជកម្មក្នុងតំបន់ ។

ទាក់ទងនឹងកំណើន គោលដៅចំបងគឺ ត្រូវជំរុញកំណើនតំបន់ភ្នំពេញ សៀមរាប និងក្រុងព្រះសីហនុ ។ ក្រុងភ្នំពេញ ដើរតួនាទីសំខាន់ក្នុងផលិតកម្មកាត់ដេរ និងការនាំចេញ ខេត្តសៀមរាបក្នុងវិស័យទេសចរណ៍វប្បធម៌ និងក្រុងព្រះសីហនុក្នុងវិស័យទេសចរណ៍តំបន់ឆ្នេរ និងផលិតកម្មប្រេងកាត ។ ខេត្តបាត់ដំបង ជាប៉ូលកំណើនមួយទៀត ដែលមានសារៈសំខាន់សំរាប់ផលិតកម្មកសិកម្ម និងពាណិជ្ជកម្ម ។

នៅក្នុងបរិបទនៃរបៀងសេដ្ឋកិច្ចមេគង្គ-តណ្ហ គោលដៅធំមួយគឺ ការតភ្ជាប់ប្រទេស កម្ពុជា មីយ៉ាន់ម៉ា ថៃ និងវៀតណាម ជាមួយប្រទេសតណ្ហ ដោយឆ្លងកាត់តាមតំបន់ឆ្នេរប៉ែកខាងកើតរបស់កម្ពុជា ក្នុងនេះមានទាំង ក្រុងព្រះសីហនុ ដែលជាកំពង់ផែសមុទ្រជ្រៅនៅកម្ពុជា ។ នាបច្ចុប្បន្ន ផ្លូវដែកតភ្ជាប់ក្រុងព្រះសីហនុ និងក្រុងភ្នំពេញ កំពុងតែកែលំអថែមទៀត ។ នៅក្រុងព្រះសីហនុ មានផែនការបង្កើតតំបន់សេដ្ឋកិច្ចពិសេស (SEZs) ច្រើនណាស់ និងគំរោងវិនិយោគខាងឧស្សាហកម្មមួយចំនួន ។ ទីនេះជាតំបន់គោលដៅទេសចរណ៍កំពុងឈានឡើង និងស្ថិតនៅជិតតំបន់ផលិតប្រេងកាត និងឧស្ម័ន ។ ខេត្តសំខាន់មួយទៀត គឺបាត់ដំបង ដែលជាចំណុចស្នូលនៃតំបន់កសិកម្មរបស់កម្ពុជា ដោយមានផលិតកម្មខ្នាតធំនូវស្រូវ ដំឡូងឈើ និងពោត ។ លក្ខណៈសំគាល់ផ្សេងៗទៀតនៃខេត្តនេះ គឺការប្រមូលផ្ដុំប្រជាជនច្រើនៗ តួនាទីជាមជ្ឈមណ្ឌលសេវាកសិកម្ម និងពាណិជ្ជកម្មដ៏សំខាន់ និងជាច្រកតភ្ជាប់ទំនាក់ទំនងយ៉ាងល្អរវាងក្រុងភ្នំពេញ និងប្រទេសថៃ ។ ស្វាយរៀង-បាវិត ជាតំបន់សំខាន់មួយទៀត ដោយសារនៅជិតកញ្ចុំឧស្សាហកម្មនៃទីក្រុងហូជីមីញ ទីក្រុងដុងណៃ ជាដើម ។ តំបន់នេះ ក៏មានសក្ដានុពលក្លាយទៅជាមជ្ឈមណ្ឌលសេវាកម្មដ៏សំខាន់ ដោយសារការរំពឹងទុកពីពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ជាមួយកញ្ចុំឧស្សាហកម្មនៅក្នុង និងនៅជុំវិញទីក្រុងហូជីមីញ ។ វិនិយោគឧស្សាហកម្ម និង SEZs មួយចំនួន ត្រូវបានគ្រោងឡើងសំរាប់តំបន់នេះ ដែលមានក្បាលដីធំៗសមស្របសំរាប់ការពង្រីកឧស្សាហកម្ម ។ សេរីសោភ័ណ-ប៉ោយប៉ែត ក៏ជាតំបន់សំខាន់មួយផ្នែកដែរ ដោយសារនៅជិតកញ្ចុំឧស្សាហកម្មក្រុងបាងកក តំបន់ឆ្នេរខាងកើត និង Chachoengsao-Prachinburi ដែលកំពុងផុសឡើង (២៥០គីឡូម៉ែត្រ) ។ តំបន់នេះមានសក្ដានុពលក្លាយទៅជាមជ្ឈមណ្ឌលសេវាកម្មដ៏សំខាន់ ដោយសារការរំពឹងទុកពីពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ជាមួយកញ្ចុំឧស្សាហកម្មនៅក្នុង និងនៅជុំវិញក្រុងបាងកក និងតំបន់ឆ្នេរខាងកើត ។ ប្រជាជនដ៏ច្រើននៅខេត្តជិតខាង គឺជាប្រភពពលកម្មមួយយ៉ាងធំ ។ ការអភិវឌ្ឍផ្លូវថ្នល់ និងផ្លូវដែកតភ្ជាប់សេរីសោភ័ណ-ប៉ោយប៉ែត និងក្រុងភ្នំពេញ ក៏ដូចជាក្រុងបាងកក ក៏មានក្នុងគំរោងដែរ ។

លោក រតនៈ បានធ្វើបទបង្ហាញ ដែលផ្ដោតលើការវិភាគពីវិស័យថាមពលនៅកម្ពុជា និងជាពិសេសអគ្គិសនីកម្ពុជា (EDC) ។ ចំពោះផលិតកម្ម និងថាមពលដែលមានសំរាប់ផ្គត់ផ្គង់នៅក្នុងប្រទេស ការកែលំអគួរកត់សម្គាល់ក្នុងប៉ុន្មានឆ្នាំថ្មីៗ ដូចមានបង្ហាញក្នុងតារាង ១ អាចអនុវត្តទៅបាន ដោយសារការបង្កើនផលិតកម្មក្នុងប្រទេសគួបផ្សំនឹងការនាំចូលអគ្គិសនីពីប្រទេសជិតខាង ។ ទិន្នន័យ (មិនបានបង្ហាញក្នុងអត្ថបទនេះទេ) បានបញ្ជាក់ដែរថា ប្រសិទ្ធភាព EDC បានកើនឡើង ពោលគឺ កំហាតប្រតិបត្តិការបានថយចុះបន្តិចក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ។

**តារាង ១: ផលិតកម្ម** EDC

| ផលិតកម្ម | ឯកតា | 2007 | 2008 | 2009 |
|---|---|---|---|---|
| សមត្ថភាពដាក់ដំឡើង | MW | 386 | 408 | 516 |
| សមត្ថភាពប្រើការបាន | MW | 356 | 373 | 473 |
| ផលិតកម្មសរុប | GWh | 1,423 | 1,622 | 1,818 |
| *ផលិតកម្មរបស់ EDC* | GWh | 294 | 163 | 100 |
| *ផលិតកម្មរបស់ IPP* | GWh | 1060 | 1190 | 1,013 |
| *ការនាំចូល* | GWh | 69 | 269 | 705 |
| ផលិតកម្មដោយ DO | GWh | 105 | 93 | 30 |
| ផលិតកម្មដោយ HFO | GWh | 1,200 | 1,190 | 1,001 |
| ផលិតកម្មដោយវារី | GWh | 49 | 47 | 47 |
| ផលិតកម្មដោយធ្យូងថ្ម | GWh | - | 23 | 34 |

តារាង ២: មូលដ្ឋានអតិថិជនរបស់ EDC

| | 2000 | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|---|
| និវាសជន | | 199,478 | 242,835 | 262,361 | 287,266 | 306,898 |
| ជនបរទេស | | 1,802 | 1,903 | 2,078 | 2,178 | 2,184 |
| ពាណិជ្ជកម្ម | | 14,292 | 17,576 | 19,698 | 23,355 | 26,543 |
| ឧស្សាហកម្ម | | 860 | 959 | 1,048 | 1,050 | 1,094 |
| ការិយាល័យរដ្ឋាភិបាល | | 1,208 | 1,526 | 1,573 | 1,684 | 1,848 |
| សរុប | 124,269 | 217,640 | 264,799 | 286,758 | 315,533 | 338,567 |

ក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ EDC អាចពង្រីកមូលដ្ឋានអតិថិជនរបស់ខ្លួនបានច្រើនប្រភេទ ។

បន្ទាប់មកទៀត លោក រតនៈ បានពិភាក្សាពីគោលដៅអភិវឌ្ឍន៍របស់ EDC/ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល សំរាប់ឆ្នាំ ២០០៩-២០១៣ ដែលរួមមាន៖

- កាត់បន្ថយចំណាយផលិតកម្ម និងបង្កើនវិសាលភាពនៃការផ្គត់ផ្គង់
- ជំរុញការនាំចូលថាមពលពីប្រទេសជិតខាង
- កសាង និងធ្វើប្រតិបត្តិការលើប្រភពថាមពលសំខាន់ៗ
- តភ្ជាប់បណ្ដាញអគ្គិសនីទូទាំងប្រទេស ពីប្រភពផលិតកម្មទៅនឹងតំបន់ទីក្រុងធំៗ
- កសាងខ្សែបញ្ជូន និងចែកចាយថាមពលនៅទូទាំងប្រទេស

សកម្មភាពអាទិភាពសំរាប់វិស័យនេះ ត្រូវបានគូសរំលេច ។ សំរាប់ប្រព័ន្ធបញ្ជូនថាមពល សកម្មភាពអាទិភាព រួមមាន៖ ការលើកកម្ពស់ស្ថិរភាព គុណភាព និងទំនុកចិត្តនៅភ្នំពេញ កណ្ដាល និងកំពង់ស្ពឺ តាមរយៈការបង្កើតគំរោងខ្សែបញ្ជូនជារង្វង់ ដោយការសាងសង់ខ្សែបញ្ជូនចំនួន ៣ គឺ (១) តាកែវ-កំពត-ក្រុងព្រះសីហនុ (២) ភ្នំពេញ-កំពង់ឆ្នាំង-ពោធិ៍សាត់(អូរសោម)-បាត់ដំបង និង (៣) ភ្នំពេញ-កំពង់ចាម និងការសាងសង់មជ្ឈមណ្ឌលបញ្ជូនអគ្គិសនីទូទាំងប្រទេស ។ សំរាប់អនុប្រព័ន្ធបញ្ជូន បច្ចុប្បន្នមានគំរោងរៀបចំសិក្ខាសាលាមួយ និងការសាងសង់អនុខ្សែបញ្ជូន ដើម្បីបង្កើនការផ្គត់ផ្គង់ថាមពលទៅតំបន់ជនបទ ។

បណ្ដាញចែកចាយ មានគោលដៅមួយចំនួន រួមមាន៖ ទទួលគ្រប់គ្រង ចាត់ចែង និងអភិវឌ្ឍន៍ប្រព័ន្ធនៅមណ្ឌលគីរី ទទួលគ្រប់គ្រង និងវិនិយោគទៅលើប្រព័ន្ធចែកចាយនៅតំបន់អប្សរា ១ និង ២ ក៏ដូចជាខេត្តសៀមរាប លុបបំបាត់ការជាវដុំ (R71) នៅ ១១៦កន្លែង ក្នុងរាជធានីភ្នំពេញ សិក្សា និងវិនិយោគទៅលើប្រព័ន្ធចែកចាយនៅរាជធានីភ្នំពេញ ដើម្បីបង្កើនស្ថិរភាព និងគុណភាពការផ្គត់ផ្គង់ និងបន្តកិច្ចប្រឹងប្រែងកាត់បន្ថយការខាតបង់ក្នុងប្រព័ន្ធចែកចាយ ព្រមទាំងចាត់វិធានការតឹងតែង ទប់ទល់នឹងការតភ្ជាប់អគ្គិសនីដោយខុសច្បាប់ ។

ផលិតកម្មថាមពល មានគោលដៅ៖ បន្តផ្ដល់អាទិភាពដល់វិនិយោគមានចំណាយទាប សំរាប់ជំនួសឲ្យផលិតកម្មមានចំណាយខ្ពស់សព្វថ្ងៃ បន្តដំណើរការសាងសង់រោងចក្រវារីអគ្គិសនី និងរោងចក្រអគ្គិសនីដុតធ្យូងថ្ម និងបង្កើនផលិតភាព ។ ការបង្កើនផលិតភាពរំពឹងថាអាចសំរេចបាន តាមរយៈការបង្កើនប្រសិទ្ធភាពការងារនៃសាខានានារបស់ EDC ដោយការសើរើរៀបចំមុខងារ កាត់បន្ថយការិយាធិបតេយ្យ និងផ្ដល់អាទិភាពដល់ការកែលំអសេវាអតិថិជន ក៏ដូចជាចូលរួមវិភាគទានខាងសង្គម ។

លោក រតនៈ បានបន្តដោយពិភាក្សាពីបញ្ហាមួយចំនួន ដែលកម្ពុជាកំពុងប្រឈម ដើម្បីសំរេចទិសដៅដូចខាងលើ ។ បញ្ហាប្រឈមទី១ គឺការអនុវត្តឱ្យបានទាន់ពេលវេលា នូវផែនការអភិវឌ្ឍន៍ឆ្នាំ២០១០-២០១៣ ។ បន្ទាប់មក គឺការស្វែងរកមូលនិធិមានលក្ខខណ្ឌសម្បទានបន្ថែមទៀត សំរាប់ពង្រីកខ្សែបញ្ជូន និងចែកចាយ ដើម្បីស្រូបយកអគ្គិសនីផលិតបាន ដូចមានចុះក្នុងកិច្ចព្រមព្រៀងទិញថាមពល (Power Purchase Agreements: PPAs) ដែលមានស្រាប់ ។ បញ្ហាប្រឈមផ្សេងទៀត រួមមាន ការកសាងសមត្ថភាពបណ្ដាញអគ្គិសនីទូទាំងប្រទេស ដើម្បីស្រូបយកអគ្គិសនីផលិតបាន និងការដាក់អនុវត្តប្រព័ន្ធគ្រប់គ្រងហានិភ័យ ដើម្បីធានាឲ្យផែនការអភិវឌ្ឍន៍អនុវត្តបានទាន់ពេល ។

លោក Kerr បានធ្វើបទបង្ហាញជាបន្ត ដោយធ្វើការពិភាក្សាពីប្រព័ន្ធផ្លូវដែកនៅប្រទេសកម្ពុជា និងបានលើកថា រដ្ឋាភិបាលកម្ពុជា បានចុះកិច្ចសន្យាម៉ៅការឱ្យក្រុមហ៊ុនអយស្ម័យយាន Toll Royal Railway ធ្វើប្រតិបត្តិការអាជីវកម្មលើបណ្ដាញផ្លូវដែកកម្ពុជា ដោយផ្ដល់សម្បទាន ផ្ដាច់មុខរយៈពេល ៣០ឆ្នាំ ។ របៀបរបបអនុវត្តគឺធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង AusAID ផ្ដល់មូលនិធិសំរាប់ការស្ដារផ្លូវដែកឡើងវិញ រីឯសម្បទានិកផ្លូវដែក (Toll) ត្រូវថែទាំហេដ្ឋារចនាសម្ព័ន្ធ និងបើកដំណើរការរថភ្លើង ហើយតាមនេះជួយរំដោះ

មូលនិធិសំរាប់អនុវត្តគំរោងឯទៀត ខាងសេដ្ឋកិច្ច និងសង្គមកិច្ច ។ គំរោងពាក់ព័ន្ធ រួមមាន៖

- ខ្សែខាងត្បូង (២៥៤គីឡូម៉ែត្រ)-ភ្នំពេញទៅកំពង់ផែក្រុងព្រះសីហនុ (ការស្តារជួសជុលខ្សែផ្លូវដែកឡើងវិញ)
- ខ្សែខាងជើង (៣៨០គីឡូម៉ែត្រ) - ភ្នំពេញទៅ សិរីសោភ័ណ្ឌ (ការស្តារជួសជុលខ្សែផ្លូវដែកឡើងវិញ)
- កំណាត់បាត់ខ្សែ (៤៨គីឡូម៉ែត្រ) - សិរីសោភ័ណ្ឌទៅប៉ោយប៉ែត (ការដាក់ខ្សែផ្លូវដែកឡើងវិញ)
- ហេដ្ឋារចនាសម្ព័ន្ធ (ឧ. ការសាងសង់ចំណតថ្មី សំរាប់ផ្ទុកទំនិញ ដឹកតាមមធ្យោបាយច្រើនបែប នៅជាយក្រុងភ្នំពេញ (សំរោង))

លោកបានបន្តធ្វើការពិចារណាពីគំនិតយល់ច្រឡំ ក្នុងការប្រៀបធៀបផ្លូវដែក ជាមួយនឹងផ្លូវថ្នល់ ព្រមទាំងផលចំណេញមួយចំនួននៃការដឹកជញ្ជូនតាមផ្លូវដែក ។ លោកបានវែកញែកថា ចំណាយប្រៀបធៀបផ្លូវថ្នល់/ផ្លូវដែក ជាទូទៅមិនបានឆ្លុះបញ្ចាំងឱ្យសព្វគ្រប់ពីបន្ទុកចំណាយនៃកត្តាខាងក្រៅ ដូចជា ការកកស្ទះ ការបំពុលបរិស្ថាន គ្រោះថ្នាក់ ការបំភាយឧស្ម័ន និងផលប៉ះពាល់ដល់សង្គម និងបរិស្ថាន នោះទេ ។ ជាផលចំណេញ លោកលើកថា ការតភ្ជាប់ផ្លូវដែក កំពង់ផែ និងចំណតផ្ទុកទំនិញដឹកតាមមធ្យោបាយច្រើនបែប បានផ្តល់នូវខ្សែរយៈផ្គត់ផ្គង់ឡូហ្ស៊ីស្ទិកដ៏រលូនមួយ ជួយកាត់បន្ថយចំណាយរបស់រដ្ឋាភិបាលលើការសាងសង់ និងថែទាំផ្លូវថ្នល់ ព្រមទាំងបង្កើតបានច្រករបៀងមួយមានសុវត្ថិភាពល្អ សំរាប់អ្នកប្រើប្រាស់ផ្លូវថ្នល់ដទៃទៀត ។ ក្រៅពីនេះ ប្រព័ន្ធផ្លូវដែកជំរុញឱ្យមានតំបន់ពាណិជ្ជកម្មឆ្លងកាត់ព្រំដែនសេរី ដោយជួយឱ្យកុងតឺនឺរអាចដឹកបានលឿន ប្រកបដោយសុវត្ថិភាព ប៉ះពាល់បរិស្ថានតិច និងសន្សំសំចៃ រវាងប្រទេសជាច្រើននៅអាស៊ី ។

លោក Kerr ជាអគ្គនាយកក្រុមហ៊ុន Toll ដែលបានទទួលសម្បទានរយៈពេល ៣០ឆ្នាំ ដើម្បីថែទាំប្រព័ន្ធផ្លូវដែក បានវែកញែកពីមូលហេតុដែលក្រុមហ៊ុនលោកចាប់អារម្មណ៍ លើឡូហ្ស៊ីស្ទិកដឹកជញ្ជូននៅកម្ពុជា ដូចតទៅ៖

- កម្ពុជា ស្ថិតក្នុងចំណោមប្រទេសមានកំណើនលឿនបំផុតនៅអាស៊ី និងកំពុងអនុវត្តកំណែទម្រង់សេដ្ឋកិច្ចសំខាន់ៗ ដើម្បីជំរុញ ការអភិវឌ្ឍ
- វិស័យឡូហ្ស៊ីស្ទិកនៅកម្ពុជា មានលក្ខណៈក្មេងខ្ចី ជាប់ដោយជំនិងទាមទារការស្តាររៀបចំយ៉ាងច្រើន ដើម្បីផ្តល់ការគាំទ្រដល់កំណើន និងការអភិវឌ្ឍនៅក្នុងប្រទេស
- Toll នឹងបង្កើតជាវិធីដឹកជញ្ជូនមួយឆ្លងកាត់មហាតំបន់មេគង្គ ហើយដឹងច្បាស់ថា កម្ពុជា និងបណ្តាញផ្លូវដែកនៅកម្ពុជាមានសារៈសំខាន់បំផុត សំរាប់គំរោងផ្លូវដែកសិង្ហបុរី-គុនមីង
- Toll នឹងរចនារៀបចំ និងដំណើរការអាជីវកម្មដឹកជញ្ជូនទំនិញតាមផ្លូវដែកមួយដែលសមស្រប មានសុវត្ថិភាពល្អ ជួយសន្សំសំចៃ និងអាចបត់បែនបាន ដែលមានសមត្ថភាពអាចផ្តល់ទុនដោយខ្លួនឯង ក្នុងរយៈពេលមធ្យមទៅរយៈពេលវែង

ដើម្បីអាចសំរេចគោលដៅកែលម្អប្រព័ន្ធផ្លូវដែកនៅកម្ពុជាបាន រាជរដ្ឋាភិបាលកម្ពុជា ត្រូវបំពេញលក្ខខណ្ឌជាច្រើន មានជាអាទិ៍៖

(ក) ផ្លូវដែកចូលដល់កំពង់ផែផ្ទាល់ - លក្ខខណ្ឌនេះត្រូវបំពេញឲ្យបាន នៅចំណតដាក់កុងតឺនឺរ នៅកំពង់ផែក្រុងព្រះសីហនុ ដោយរដ្ឋាភិបាល ត្រូវគាំទ្រតាមការយល់ព្រមឲ្យមានផ្លូវដែកចូលដល់ផ្ទាល់

(ខ) ការទូទាត់ពន្ធគយ - កុងតឺនឺរត្រូវអាចដឹកជញ្ជូនតាម ផ្លូវដែកក្រោមត្រាបញ្ជាក់ពីគយបាន (under-bond)

(គ) ឧបត្ថម្ភធនលើប្រេងឥន្ធនៈ - លក្ខខណ្ឌនេះត្រូវដាក់អនុវត្តចំពោះសម្បទានិកផ្លូវដែក ពីព្រោះរថភ្លើងរត់មួយជើងៗ អាចជំនួសការដឹកជញ្ជូនលើផ្លូវថ្នល់ តាមរថយន្តកាមីញ៉ុងធំៗ ចំនួន ១០០ជើង

(ឃ) ត្រូវកសាងកំណាត់ផ្លូវដែលបាត់នៅក្នុងប្រទេសថៃ

(ង) បែបបទគយ និងការយកពន្ធលើការឆ្លងកាត់ព្រំដែន - កិច្ចព្រមព្រៀងសំរាប់ទំនិញដឹកតាមផ្លូវដែក ត្រូវចរចាគ្នាតាំងពីពេលនេះទៅ

(ច) ប្រព័ន្ធច្បាប់រឹងមាំ - លក្ខខណ្ឌនេះ រួមមាន ការចុះបញ្ជីរថយន្តដឹកជញ្ជូន ការសាយភាយប្រេងឥន្ធនៈ បញ្ហាខាងបរិស្ថាននិងសង្គម និង

(ឆ) ស្តង់ដារសុវត្ថិភាពផ្លូវតឹងរ៉ឹង - លក្ខខណ្ឌទាំងនេះ ត្រូវដាក់អនុវត្តធ្វើការត្រួតពិនិត្យ និងពង្រឹង ហើយរាល់ប្រតិបត្តិការខុសច្បាប់ត្រូវតែបញ្ឈប់ ។

ជាចំណែកមួយនៃវិភាគទានរបស់ខ្លួន Toll នឹងកសាងកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សមួយ ដែលមានខ្លឹមសារដូចតទៅ៖

- ហានិភ័យ និងសុវត្ថិភាព - គោលដៅ គឺការខាតបង់ពេលវេលាដោយរបួសកម្រិតសូន្យ
- សម្ភារៈការពារបុគ្គល - ណែនាំបង្ហាញ ដាក់អនុវត្ត និងពង្រឹងអនុវត្ត
- ការបណ្តុះបណ្តាលផ្អែកលើសមត្ថភាព - អភិវឌ្ឍ និងផ្តល់ជូនសំរាប់វិស័យនីមួយៗ
- ការអនុវត្តល្អខាងបរិស្ថាន - អភិវឌ្ឍប្រព័ន្ធ និងធានាការប្រតិបត្តិតាម
- ការពិនិត្យសុខភាព - មុនពេលឲ្យចូលធ្វើការ និងតាមពេលកំណត់
- ការយល់ដឹងរបស់សហគមន៍ - ត្រូវបង្កើតកម្មវិធីផ្សេងៗ និងធ្វើការបង្ហាញជូននៅតាមបណ្តាញផ្លូវដែក

លោក Kerr បានបញ្ចប់បទបង្ហាញ ដោយវែកញែកថា រាជរដ្ឋាភិបាលកម្ពុជាត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីដោះស្រាយបញ្ហាខាងគោលនយោបាយនៅពេលនេះតែម្តង បើពុំនោះទេ ធនាគារអភិវឌ្ឍន៍អាស៊ី AusAID និងវិស័យឯកជន នឹងត្រូវចំណាយអស់ជាង ២០០លានដុល្លារ ដើម្បីស្តារកសាងឡើងវិញនូវបណ្តាញផ្លូវដែកមួយ ដែលមិនអាចធ្វើអាជីវកម្មដឹកជញ្ជូនទំនិញឲ្យរស់រាន និងមានចីរភាព ជាលក្ខណៈពាណិជ្ជកម្មបាន ។ ដូច្នេះ ត្រូវចាត់វិធានការជាបន្ទាន់ ។